## ការផ្គត់ផ្គង់ផ្នែកសង្គម

កម្មវិធីផ្គត់ផ្គង់ផ្នែកសង្គមគឺជាកម្មវិធីមើលថែសហគមន៍ និងផ្ទះសម្បែង (HACC) ដែលទទួលការឧបត្ថម្ភផ្នែកថវិកា ហើយផ្ដល់ជាចម្បង ដើម្បីបំពេញទៅលើសេចក្ដីត្រូវការរបស់បុគ្គលសំរាប់ការទាក់ទងផ្នែកសង្គម ដោយផ្ដល់នូវការអាណិតអាសូរទោះថានៅបរិដ្ឋានតាមផ្ទះ ឬទទួលកិច្ចបំរើសហគមន៍ក្ដី។ ការផ្គត់ផ្គង់ផ្នែកសង្គមមានផ្ដល់ទៅតាមមូលដ្ឋានម្នាក់សំរាប់ម្នាក់ ឬជាក្រុមតូចដែលមានការចូលចិត្តរួមមាននៅក្នុងក្រុម។

ការផ្គត់ផ្គង់ផ្នែកសង្គម មានគោលដៅដើម្បីបង្កើនជាអតិបរិមានូវសមត្ថភាពរបស់បុគ្គលម្នាក់ៗ ឲ្យបន្តការរស់នៅដោយឯករាជ្យតាមផ្ទះ ហើយដើម្បីជួយក្នុងការបំពេញទៅលើសេចក្ដីត្រូវការរបស់បុគ្គលសំរាប់ការផ្គត់ផ្គង់ផ្នែកសង្គម។

អស់អ្នកដែលទទួលកិច្ចបំរើផ្គត់ផ្គង់ផ្នែកសង្គម នឹងត្រូវគេគិតថ្លៃចំនួន៤ដុល្លា ក្នុង១ម៉ោង។ នៅក្រោមកាលៈទេសៈធម្មតា អតិថិជនម្នាក់ៗនឹងទទួលជំនួយចំនួន៣ម៉ោង ក្នុង១អាទិត្យ។

អស់អ្នកដែលមានសេចក្ដីត្រូវការទទួលយកកិច្ចបំរើ គេអាចបញ្ជូនខ្លួនឯងផ្ទាល់ទៅឯកម្មវិធី ឬឲ្យគ្រួសារ មិត្តភក្ដិ បុគ្គលិកសហគមន៍ អ្នកវិជ្ជាជីវៈផ្នែកសុខភាព ឬស្ថាប័នផ្ដល់កិច្ចបំរើបញ្ជូនខ្លួនទៅឯកម្មវិធីក៏បានដែរ។

**MCCS មានបុគ្គលិកដែលចេះនិយាយពីរភាសា និងបុគ្គលិកផ្គត់ផ្គង់ដែលចេះនិយាយភាសាៈ**

អារ៉ាប់ អាស៊ីរី បូស្នៀ ចិន ក្រូអេហ្សិន ហ្វីលីពីន ហ៊ីនឌី ខ្មែរ លាវ ម៉ាសេដូន ស៊ើប អេស្ប៉ាញ៉ុល វៀតណាម និងភាសាអាណិកជនដទៃទៀត។

ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀត សូមទាក់ទងៈ

កិច្ចបំរើមើលថែសហគមន៍ពហុវប្បធម៌

**30 Hallstrom Place**

**Wetherill Park NSW 2164**

ទូរស័ព្ទៈ **(02) 8717 1500**

ទូរសារៈ **(02) 9725 2141**

អ៊ីម៉ែលៈ **info@agedcc.org.au**

ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា

សូមទូរស័ព្ទលេខ

**13 14 50**

និយាយប្រាប់គេអំពីភាសាណាមួយដែលលោកអ្នកនិយាយ

រួចស្នើសុំឲ្យគេទូរស័ព្ទទៅ

កិច្ចបំរើមើលថែសហគមន៍ពហុវប្បធម៌

លេខ **8717 1500**

ទទួលការឧបត្ថម្ភថវិកាពីក្រសួងសុខភាព
និងការចូលវ័យចាស់ និងក្រសួងមើលថែមនុស្សចាស់
ពិការភាព និងផ្ទះសម្បែង

**M.C.C.S**

**MULTICULTURAL COMMUNITY CARE SERVICE**

**KHMER**

# ជួយដើម្បីឱ្យអាចរស់នៅដោយឯករាជ្យ

**30 Hallstrom Place**
**WETHERILL PARK**

ទូរស័ព្ទៈ **(02) 8717 1500**

ទូរសារៈ **(02) 9725 2141**

អ៊ីម៉ែលៈ **info@agedcc.org.au**

សាខានៃមជ្ឈមណ្ឌលសហគមន៍

**Cabramatta**

## កិច្ចបំរើមើលថែសហគមន៍ពហុវប្បធម៌

MCCS គឺជាផ្នែកនៃមជ្ឈមណ្ឌលសហគមន៍ Cabramatta ជាអង្គការមិនរកប្រយោជន៍ផ្ទាល់ខ្លួន មានមូលដ្ឋាននៅតាមសហគមន៍។

កិច្ចបំរើផ្តល់នូវការមើលថែផ្ទាល់ទៅដល់មនុស្សចាស់ជរា ប្រជាជនដែលមានពិការភាព និងអ្នកមើលថែមកពីសាវតារវប្បធម៌ និងភាសាផ្សេងៗ (CALD)។ ការនេះអាចសំរេចបានតាមរយៈកម្មវិធីខុសៗគ្នាចំនួន៤:

- កញ្ចប់មើលថែមនុស្សចាស់ក្នុងសហគមន៍ (CACP)
- ការមើលថែមនុស្សចាស់តាមផ្ទះយ៉ាងធំទូលាយ (EACH)
- ការមើលថែជំនួសបណ្តោះអាសន្នសំរាប់សហគមន៍ CALD
- ការផ្គត់ផ្គង់ផ្នែកសង្គម

កម្មវិធីទាំង៤នេះ ផ្តល់នូវកិច្ចបំរើទៅដល់ប្រជាជនដែលរស់នៅក្នុងសាលាសង្កាត់ Liverpool, Fairfield និង Bankstown។

## កញ្ចប់មើលថែមនុស្សចាស់ក្នុងសហគមន៍ (CACP)

កញ្ចប់មើលថែមនុស្សចាស់ក្នុងសហគមន៍ បានទទួលការឧបត្ថម្ភថវិកាពីក្រសួងសុខភាព និងការចូលវ័យចាស់ ដោយមានគោលបំណងដើម្បីផ្តល់នូវវិធីមួយផ្សេង ក្រៅពីការមើលថែនៅតាមផ្ទះសំណាក់ ហេតុដូច្នេះជួយឲ្យអតិថិជនដែលមានសេចក្តីត្រូវការមើលថែស្មុគស្មាញ ឲ្យគេអាចរក្សានៅតាមផ្ទះរបស់ខ្លួនយ៉ាងយូរតាមដែលអាចធ្វើទៅបាន។

ដើម្បីទទួល CACP ត្រូវឲ្យមានការបាន់ស្មង់ ជាទូទៅការនេះធ្វើឡើងដោយក្រុមប៉ាន់ស្មង់ការមើលថែមនុស្សចាស់។

CACP ត្រូវផ្តល់នៅតាមផ្ទះអតិថិជន ដោយបុគ្គលិកផ្គត់ផ្គង់មនុស្សចាស់ចេះនិយាយពីរភាសាដែលទៅជួបអតិថិជនពីរ ទៅបីដងក្នុង១អាទិត្យ។ កិច្ចបំរើនឹងធ្វើការជាមួយអតិថិជន និងសមាជិកគ្រួសារដើម្បីបង្កើតនូវគំរោងមើលថែមួយ ដែលបំពេញទៅលើសេចក្តីត្រូវការរបស់អតិថិជន។

ពុំមានការគិតថ្លៃដែលនឹងនរ សំរាប់កិច្ចបំរើឡើយដោយព្រោះថាករណីនីមួយៗត្រូវបានប៉ាន់ស្មង់ដោយផ្ទាល់ៗ។ តម្លៃច្រើនបំផុតគឺ១៧.៥ភាគរយ នៃប្រាក់សោធនរបស់លោកអ្នក។

## ការមើលថែមនុស្សចាស់តាមផ្ទះយ៉ាងធំទូលាយ (EACH)

កញ្ចប់ EACH បានទទួលការឧបត្ថម្ភថវិកាពីក្រសួងសុខភាព និងការចូលវ័យចាស់ ដោយមានគោលបំណងដើម្បីផ្តល់នូវកិច្ចបំរើជំនួយតាមផ្ទះដែលមានកំរិតខ្ពស់ ដើម្បីជួយប្រជាជនចាស់ៗដែលមានសេចក្តីត្រូវការមើលថែកំរិតខ្ពស់មួយចំនួន។ អតិថិជនដែលទទួលកិច្ចបំរើនេះ តម្រូវឲ្យមានជំនួយមើលថែដែលមានមូលដ្ឋានតាមផ្ទះ ក៏ប៉ុន្តែមានបំណងចង់រក្សានៅតាមផ្ទះរបស់ខ្លួនយ៉ាងយូរតាមដែលអាចធ្វើទៅបាន។

ដើម្បីទទួលយកកញ្ចប់ EACH បុគ្គលត្រូវតែបានប៉ាន់ស្មង់ដោយក្រុមប៉ាន់ស្មង់ការមើលថែមនុស្សចាស់។

ដូចគ្នានឹង CACP ដែរពុំមានការគិតថ្លៃនឹងនរសំរាប់កិច្ចបំរើឡើយដោយព្រោះថាករណីនីមួយៗត្រូវបានប៉ាន់ស្មង់ផ្ទាល់ៗខ្លួន។ តម្លៃច្រើនបំផុតគឺ១៧.៥ភាគរយ នៃប្រាក់សោធនរបស់លោកអ្នក។

ដើម្បីទទួលការប៉ាន់ស្មង់ សូមទាក់ទង:

**មជ្ឈមណ្ឌលផ្នែកបញ្ជូន និងផ្តល់ព័ត៌មាន (RIC)**

ថ្ងៃច័ន្ទ ទៅថ្ងៃសុក្រ

ម៉ោង១០ព្រឹក-ម៉ោង៤រសៀល

ទូរស័ព្ទ: **1800 455 511**

## ការមើលថែជំនួសបណ្តោះអាសន្ន

ការមើលថែជំនួសបណ្តោះអាសន្ន គឺជាកម្មវិធីឧបត្ថម្ភថវិការបស់ HACC ដែលផ្គត់ផ្គង់ដល់អ្នកមើលថែ CALD ដោយផ្តល់នូវការមើលថែជំនួសបណ្តោះអាសន្នទៅដល់មនុស្សចាស់ និងប្រជាជនដែលមានពិការភាពផ្នែករាងកាយ និងសតិបញ្ញាដែលខ្លួនត្រូវបានគេមើលថែ។ ការមើលថែជំនួសបណ្តោះអាសន្នត្រូវបានផ្តល់នៅតាមផ្ទះអតិថិជន ដែលអ្នកមើលថែធម្មតារបស់ខ្លួនពុំមានវត្តមាននៅជាមួយគេ។

នរណាក៏ដោយដែលត្រូវការការមើលថែជំនួសបណ្តោះអាសន្នអាចឲ្យគេបញ្ជូនទៅកម្មវិធីនេះ។ ការបញ្ជូនពីអ្នកមើលថែដោយខ្លួនឯង គ្រួសារ ឬមិត្តភក្តិរបស់ខ្លួន បុគ្គលិកសហគមន៍ អ្នកវិជ្ជាជីវៈផ្នែកសុខភាព ឬស្ថាប័នផ្តល់កិច្ចបំរើឯទៀត នឹងត្រូវបានគេទទួលយក។

ពេលណាជនណាម្នាក់ត្រូវបានចាត់ទុកថាមានសិទ្ធិទទួល ហើយមានទីកន្លែងទំនេរសំរាប់គេ នោះការប៉ាន់ស្មង់អតិថិជននឹងត្រូវធ្វើឡើង ហើយគំរោងមើលថែសមស្របមួយនឹងត្រូវរៀបចំដោយភ្នាក់ងារប៉ាន់ស្មង់ការមើលថែជំនួសបណ្តោះអាសន្ន និងផ្នែកសម្ព័ន្ធការមុនការចាប់ផ្តើមនៃកិច្ចបំរើ។

អស់អ្នកដែលទទួល ការមើលថែជំនួសបណ្តោះអាសន្ននៅតាមផ្ទះនឹងត្រូវបានគេស្នើសុំឲ្យធ្វើវិភាគទាន ចំនួន៣ដុល្លាក្នុង១ម៉ោង។

កិច្ចបំរើមើលថែជំនួសបណ្តោះអាសន្ន អាចមាន:

- **ជំនួយសំរាប់គ្រាមានអាសន្ន / នៅពេលមានវិបត្តិ**
- **ការមើលថែជំនួសបណ្តោះអាសន្នដែលបានគោងទុក / រយះពេលខ្លី**
- **ការមើលថែជំនួសបណ្តោះអាសន្នរយះពេលវែង / ជាបន្តបន្ទាប់**